**Embassy of Japan**

**in the Kingdom of Cambodia**

# Press Release

No. 15 PR-18/EoJ 1 March, 2018

## Japanese Film Festival 2018 in Siem Reap

The Japan Foundation and the Embassy of Japan, in cooperation with the Ministry of Culture and Fine Arts and Cambodia-Japan Cooperation Center (CJCC) will organize the **"Japanese Film Festival 2018 in Siem Reap"** from 2 to 4 March 2018, at the Major Cineplex in Siem Reap.

During the three-day, Japanese films selected from a wide range of different categories will be screened at the above-mentioned theater in Siem Reap. As the selection includes cartoon, drama, documentary films and some of which are awarded-winning films, with these film portraying various aspects of Japanese life, society and culture, the Festival will provide a good opportunity for audience to familiarize themselves with Japan and its people.

The 12 Japanese films will be screened with Khmer and English Subtitles. Screening schedule brochure is published at the Japanese Film Festival website at the following link: http://kh.japanesefilmfest.org/wp-content/uploads/2018/02/JFF2018-SRP-Brochure.pdf

Japanese Film Festival is held every year since 2015 to promote the understanding of Japanese life and culture through film screening among Cambodian people.

For inquiry, please contact to the Culture and Information Section of the Embassy of Japan at 023 217 161, (Ext. 1121) or Email: info.jpn@pp.mofa.go.jp.

## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## សេចក្តីប្រកាសព័ត៌មាន

No. 15 PR-18/EoJ

ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

# មហោស្រពភាពយន្តជប៉ុនប្រចាំឆ្នាំ២០១៨ នៅខេត្តសៀមរាប

មូលនិធិជប៉ុន និងស្ថានទូតជប៉ុន រួមសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន នឹងរៀបចំមហោស្រពភាពយន្តជប៉ុន២០១៨ នៅខេត្តសៀមរាប ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៨ នៅរោងភាពយន្ត Major Cineplex នៃខេត្តសៀមរាប។

កំឡុងរយៈពេលបីថ្ងៃ មានភាពយន្តជាច្រើនប្រភេទដែលត្រូវបានសម្រិតសម្រាំង សម្រាប់ការដាក់បញ្ចាំងនៅរោងភាពយន្តក្នុងខេត្តសៀមរាបដូចដែលបានជម្រាបជូនខាងលើ។ ភាពយន្តទាំងនោះរួមមាន ភាពយន្តគំនូរជីវចល ភាពយន្តបែបមនោសញ្ចេតនា ភាពយន្តឯកសារ ហើយក្នុងនោះមានខ្សែភាពយន្តខ្លះធ្លាប់ទទួលបានពានរង្វាន់ផងដែរ។ ភាពយន្តដែលនឹងត្រូវចាក់បញ្ចាំងនេះ ឆ្លុះបញ្ចាំងអំពីជីវភាពរស់នៅរបស់ប្រជាជនជប៉ុន សង្គម និងវប្បធម៌ជប៉ុន ហើយមហោស្រពនេះក៏ផ្តល់ឱកាសដ៏ល្អមួយសម្រាប់អ្នកទស្សនាដើម្បីអាចស្គាល់ពីប្រទេស និងប្រជាជនជប៉ុន។

សម្រាប់ឆ្នាំនេះភាពយន្តជប៉ុនចំនួន១២រឿង នឹងត្រូវបានចាក់បញ្ចាំងជាមួយចំណងជើងរងជាភាសាខ្មែរ និង ភាសាអង់គ្លេស។ សម្រាប់កម្មវិធីលម្អិតនៃការចាក់បញ្ចាំងមានផ្សព្វផ្សាយនៅលើគេហទំព័រនៃមហោស្រពភាពយន្តជប៉ុន៖http://kh.japanesefilmfest.org/wp-content/uploads/2018/02/JFF2018-SRP-Brochure.pdf

មហោស្រពភាពយន្តជប៉ុន ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០១៥មក ក្នុងគោលបំណងជំរុញការយល់ដឹងអំពីជីវភាពរស់នៅរបស់ប្រជាជននិងវប្បធម៌ជប៉ុនដល់ប្រជាជនកម្ពុជា តាមរយៈការចាក់បញ្ចាំងភាពយន្ត។

ចំពោះសំណួរផ្សេងៗ សូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈលេខទូរស័ព្ទ ០២៣ ២១៧ ១៦១ (ភ្ជាប់បន្ត ១១២១) រឺក៏ផ្ញើអ៊ីម៉េលមកកាន់អាស័យដ្ឋានដូចខាងក្រោម៖ info.jpn@pp.mofa.go.jp ។

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161, Fax: 023 216 162*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*